ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១៧...សសរ

# សេចក្តីសម្រេច

## ស្តីពីការបង្កើតក្រុមការងារចុះរៀបចំកិច្ចការសន្តិសុខ សុវត្ថិភាព តាមគោលដៅប្រារព្ធពិធី ក្នុងព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើប្រាស់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់ របស់រាជរដ្ឋាភិបាលកម្ពុជា

## ស ម្រេ ច

**ប្រការ ១ :** បង្កើតក្រុមការងារចុះរៀបចំកិច្ចការ សន្តិសុខ សុវត្ថិភាព ដែលមានសមាសភាពដូចខាងក្រោម៖

| | | | | | |
|---|---|---|---|---|---|
| ១. | ឯកឧត្តម នាយឧត្តមសេនីយ៍ | ឃួ | ស៊ុនឡុង | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | ប្រធាន |
| ២. | ឯកឧត្តម នាយឧត្តមសេនីយ៍ | ហ៊ីង | ប៊ុនហៀង | អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជានាយកងឧទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៣. | ឯកឧត្តម នាយឧត្តមសេនីយ៍ | ហ៊ុយ | ពិសិដ្ឋ | អនុរដ្ឋលេខាធិការក្រសួងការពារជាតិ និងជានាយករងឧទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៤. | ឯកឧត្តម | ហ៊ុន | ស៊ីថា | នាយកងឧទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី | សមាជិក |
| ៥. | ឯកឧត្តម ឧត្តមសេនីយ៍ឯក | ទូច | ណារ៉ុថ | អគ្គស្នងការរងនគរបាលជាតិ និងជាប្រធាននាយកដ្ឋានអង្គរក្ស | សមាជិក |
| ៦. | ឯកឧត្តម ឧត្តមសេនីយ៍ឯក | ហ៊ុន | ម៉ាណែត | នាយរងសេនាធិការចំរុះ មេបញ្ជាការរងកងទ័ពជើងគោក និងជាមេបញ្ជាការបញ្ជាការដ្ឋាន ជាតិកំលាំងពិសេសប្រឆាំងភេរវកម្ម | សមាជិក |

| | | | | | |
|---|---|---|---|---|---|
| ៧. | ឯកឧត្តម ឧត្តមសេនីយ៍ឯក | ចៅ | តុលា | នាយរងសេនាធិការចំរុះ នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស | សមាជិក |
| ៨. | ឯកឧត្តម ឧត្តមសេនីយ៍ឯក | អ៊ុង | សារិទ្ធ | នាយរងសេនាធិការចំរុះ នៃកងយោធពលខេមរភូមិន្ទ មេបញ្ជាការរង និងជានាយសេនាធិការ បញ្ជាការដ្ឋានអង្គរក្ស | សមាជិក |
| ៩. | ឯកឧត្តម ឧត្តមសេនីយ៍ឯក | ទិសុទ្ធ | សំបូរ | មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស | សមាជិក |
| ១០. | ឯកឧត្តម ឧត្តមសេនីយ៍ឯក | ម៉ែ | សារឿន | មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស | សមាជិក |
| ១១. | ឯកឧត្តម ឧត្តមសេនីយ៍ឯក | គោគ | ចន្ថា | មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស និងជាមេបញ្ជាការ ការពារគោលដៅទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១២. | ឯកឧត្តម ឧត្តមសេនីយ៍ឯក | អន | សារិទ្ធ | មេបញ្ជាការរង បញ្ជាការដ្ឋានជាតិកំលាំងពិសេសប្រឆាំងភេរវកម្ម | សមាជិក |
| ១៣. | ឯកឧត្តម ឧត្តមសេនីយ៍ទោ | នន់ | សុខា | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៤. | ឯកឧត្តម ឧត្តមសេនីយ៍ទោ | អ៊ុង | ជំនោរ | ប្រធានក្រុមបច្ចេកទេសរុករកជាតិផ្ទុះកែច្នៃ (IED) | សមាជិក |

**ប្រការ ២ :** ក្រុមការងារ មានភារកិច្ច ៖

- ចុះគ្រប់គោលដៅប្រារព្ធពិធីផ្សេងៗ របស់សម្ដេចតេជោ នាយករដ្ឋមន្ត្រី និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត
- ដឹកនាំបញ្ជា និងសហការជាមួយសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ព្រមទាំងអាជ្ញាធរដែនដី លើការងារសន្តិសុខ សុវត្ថិភាព
- ដោះស្រាយ និងទប់ស្កាត់រាល់បញ្ហាដែលកើតមានឡើងដោយយថាហេតុ ក្នុងកម្មវិធីនីមួយៗ
- បំពេញកិច្ចការផ្សេងៗទៀត ដែលពាក់ព័ន្ធ និងកិច្ចការសន្តិសុខ សុវត្ថិភាព ជូនដល់សម្ដេចតេជោ នាយករដ្ឋមន្ត្រី និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ។

**ប្រការ ៣ :** អនុប្រធាន និងសមាជិក ត្រូវចូលរួមប្រជុំតាមការអញ្ជើញពីប្រធានក្រុមការងារចុះរៀបចំកិច្ចការ សន្តិសុខ សុវត្ថិភាព ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**កន្លែងទទួល**

- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ក្រសួងការពារជាតិ
- ក្រសួងមហាផ្ទៃ
- អគ្គបញ្ជាការដ្ឋាន ខ.ភ.ម
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- គណៈបញ្ជាការឯកភាពរាជធានី-ខេត្ត
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០១៥

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**